ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តកណ្តាល
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៥២ អក ចុះថ្ងៃទី ០៧
ខែ កក្កដា ឆ្នាំ ១៩៩៥
ជំនុំជំរះ
លេខ ១០៥ ភ ចុះថ្ងៃទី ២១
ខែ ធ្នូ ឆ្នាំ ១៩៩៥
សាលក្រម
លេខ ១០២ ភ ចុះថ្ងៃទី ២១
ខែ ធ្នូ ឆ្នាំ ១៩៩៥

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តកណ្តាល

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកណ្តាល នាថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៥ ដោយមាន :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្តកណ្តាល

**ដើម្បីជំនុំជំរះ :**

១-ជនជាប់ចោទឈ្មោះ ច សុផ អាយុ ២៣ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា សាសនាព្រះពុទ្ធ ។ កិរិតវប្បធម៌ថ្នាក់ទី ០៨ថ្មី ។ កំណើតនៅភូមិពូ ឃុំដង្កោ ស្រុកដង្កោ ខេត្តកណ្តាល ។ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៨E₀ ផ្លូវលេខ ១១១ សង្កាត់ដេប៉ូ II ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ ច ស (រ) ម្តាយឈ្មោះ ះ ះ (ស) ប្រពន្ធឈ្មោះ ស ខះ មានកូន ០២នាក់ ។ ទោសពីមុនគ្មាន ។

២-ឈ្មោះ អ ឧ អាយុ ២៣ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា សាសនាព្រះពុទ្ធ ។ លំនៅកំណើតភូមិចំបក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ទីលំនៅសព្វថ្ងៃសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ របររកស៊ីកម្មករ ។ ឪពុកឈ្មោះ ស អ (រ) ម្តាយឈ្មោះ ស ច(ស) ប្រពន្ធឈ្មោះ ៩ ៩ទ មានកូន ០១នាក់ ។ ទោសពីមុន គ្មាន ។

៣-ឈ្មោះ ៩ សរ ហៅ គ អាយុ ២៣ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា សាសនាព្រះពុទ្ធ របររកស៊ីជាងផ្ទះ ។ ទីលំនៅកំណើតសង្កាត់លេខ II ភ្នំពេញ ។ ទីលំនៅសព្វថ្ងៃផ្ទះលេខ ២៥ ភូមិទួលសង្កែ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ ៩ យ (រ) ម្តាយឈ្មោះ ឧ ម ។ នៅលីវ ទោសពីមុនគ្មាន ។

៤-ឈ្មោះ ឆ (គ្មានសាវតារជាតិ) គេចខ្លួន ។

ត្រូវចោទពីបទ : ប្លន់ទ្រព្យសម្បត្តិប្រជាជន កាលពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ប្រព្រឹត្តនៅភូមិ ចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។



សាលក្រមនេះចូលជាសាលក្រមស្ថាពរនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ដោយគូភាគីពុំបានចូលមកប្តឹងតវ៉ាក្នុងកាលកំណត់របស់ច្បាប់ទេ ។

បានឃើញ
ប្រធានតុលាការខេត្តកណ្តាល
[redacted]

កណ្តាល.ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦
ក្រឡាបញ្ជី
[redacted]

Scanned with CamScanner

-តុលាការខេត្តកណ្តាលបានចាត់តាំងលោ[redacted] សុគំគ្រ ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ ច សជ, អ ឆ, និងឈ្មោះ ឋ សរ ។ តាមដីកាចាត់តាំងលេខ ៣៣ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥ ។

-តាមកំណត់ហេតុ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ និងយោងតាមដីកាសន្និដ្ឋានចោទប្រកាន់លេខ ២៩១ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់អយ្យការអមតុលាការខេត្តកណ្តាល ។

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ :

-នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ វេលាម៉ោង ១:៣០នាទីអាធ្រាត្រ នៅផ្ទះរបស់ឈ្មោះ ត គ នៅភូមិចន្ទក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានជនម្នាក់មិនស្គាល់មុខ បានចូលក្នុងផ្ទះទាញផ្តាច់ខ្សែមុងដែល ត គ កំពុងដេកយកកាំភ្លើងខ្លីភ្ជង់ក្របៀកម្ចាស់ផ្ទះ ហើយជនម្នាក់ទៀត ស្លៀកខោខ្លីគ្មានពាក់អាវ បានស្ទុះទៅចាប់ដៃ ត គ ទាំងពីរចងនឹងសារុង រួចអូសចងនឹងសសរផ្ទះកណ្តាល ហើយវាដើររុករើពេញក្នុងផ្ទះ ចំណែកជនដែលកាន់អាវុធនៅតែភ្ជង់ដដែល ហើយសំឡុតម្ចាស់ផ្ទះយកមាសអោយវា បន្ទាប់មកស្ទុះទៅភ្ជង់ប្រពន្ធម្ចាស់ផ្ទះហើយត្រឡប់មកភ្ជង់ ត គ វិញ ពេលនោះម្ចាស់ផ្ទះឃើញថាវាម្នាក់ទៀត ស្លៀកខោខ្លីពាក់អាវមិនដឹងពណ៌ មានស្តើងសំបុរខ្មៅដើររុករើពេញតែក្នុងផ្ទះអស់រយៈពេលជាងកន្លះម៉ោង ពួកវាក៏ចុះពីលើផ្ទះចុះទៅវិញបាត់ទៅ ។ ពេលនោះប្រពន្ធកូនបានមកស្រាយចំណង ត គ ហើយនិយាយប្រាប់ប្តីថា ពួកវាយកមាសអស់ចំនួន ០៥ជី និងប្រាក់ ២៤ម៉ឺនរៀល រួចហើយ ត គ បានស្រែកឱ្យញាតិជិតខាងជួយ ។

-បានឃើញកំណត់ហេតុដកហូតវត្ថុតាងនៅផ្ទះជនរងគ្រោះ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ។

-បានឃើញកំណត់ហេតុដកហូតសម្ភារៈ ពីជនល្មើសឈ្មោះ អ ឆ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់នគរបាលរាជធានីភ្នំពេញ ។

-បានឃើញកំណត់ហេតុទទួលស្គាល់វត្ថុតាង ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់នគរបាលស្រុកកៀនស្វាយ ។

-បានឃើញលិខិតសុំវត្ថុតាងរបស់ឈ្មោះ ត គ ជាជនរងគ្រោះ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

-បានឃើញលិខិតប្រគល់ភស្តុតាង ឱ្យទៅជនរងគ្រោះឈ្មោះ ត គ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ក្រឡាបញ្ជីតុលាការខេត្តកណ្តាល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ អ ឆ បានឆ្លើយថា : នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៥ រូបខ្លួនបានទៅកៀនស្វាយ ម៉ុផ្ទះ ត គ ជាមួយឈ្មោះ ឋ សរ, ច សជ និងឈ្មោះ ឆ លុះដល់ល្ងាចខ្លួនត្រឡប់មកវិញ ។ ត គ ពុំមានជាប់សាច់ញាតិអ្វីនឹងខ្លួនទេ ។ ស្អែកឡើងនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ម៉ោង ៥:០០ល្ងាច ខ្លួនទៅបួននាក់ដដែលដោយមានឈ្មោះ ឆ ជាអ្នកដឹកនាំ ដល់ម៉ោង ៦:៣០នាទី ដល់គគីរ នាំគ្នាអង្គុយលើសាលាឆទាន ។ ពេលនោះឈ្មោះ ឆ និយាយថា យប់នេះទៅប្លន់គេយកលុយចាយ លុះម៉ោង ១:៣០នាទីយប់ ខ្លួននាំអ្នកទាំងបីទៅផ្ទះ ត គ ដោយឈ្មោះ ឆ មានកាំភ្លើង K៥៤ មួយដើមនឹងគ្រាប់១០គ្រាប់ ។ ពេលទៅដល់ចូលទៅក្នុងផ្ទះបីនាក់ ចំណែកខ្លួនឈរយាមនៅខាងក្រៅប៉ែកខាងក្រោយផ្ទះ អស់មួយសន្ទុះធំឈ្មោះ ឆ, សរ, ជ ចេញមក ហើយចុះដីទាំងអស់គ្នា



Scanned with CamScanner

រួចទៅជួបជុំគ្នានៅក្រោយវត្តស្លាកែត ពេលនោះ **ឆ** ប្រាប់ថាមានលុយ ២០ម៉ឺនរៀល ក្រវិល០១គូ ចិញ្ចៀន០១វង់ ។ រួចហើយនាំទៅភ្នំពេញនៅម៉ោង ៧:៣០នាទីព្រឹក ហើយឈ្មោះ **ឆ** ចែកប្រាក់ឱ្យម្នាក់ៗ ៣៥០០០រុ០០ តែនៅឈ្មោះ **ឆ** មានចិញ្ចៀននឹងក្រវិល រួចក៏នាំខ្លួនទៅលក់នៅផ្សារចាស់ មិនទាន់បានលក់ផងស្រាប់តែនគរបាលចាប់រូបខ្លួនតែម្តង ចំណែកឈ្មោះ **ឆ** រត់ចូលទៅក្នុងផ្សារបាត់ ខ្លួនត្រូវចាប់នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩៥ យកមកឃុំឃាំងនៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

-ជនជាប់ចោទឈ្មោះ **ច សផ** បានឆ្លើយថា : នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៥ ខ្លួនបានទៅកៀនស្វាយ មានគ្នា ០៤នាក់ គឺឈ្មោះ **ឆ**, រូបខ្លួន, **ថ សរ**, និង **អ ឩ** ទាំងបួននាក់ទៅលេងផ្ទះ **អ ឩ** ជិតផ្ទះម្ចាស់របស់ ។ លុះស្អែកឡើងនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ខ្លួនទាំងបួននាក់ក៏ជិះរ៉ឺម៉កទៅម្តងទៀត ដោយ **អ ឩ** ស្គាល់ម្ចាស់ផ្ទះ ហើយបបួលទៅប្លន់ ក្រុមខ្លួនមានកាំភ្លើង K៥៤ មួយដើម មានគ្រាប់មួយបង់ ។ ពេលទៅដល់ចូលខារ៉ាអូខេម៉ុមណ្ឌលពិការ ច្រៀងរហូតដល់ម៉ោង ១:៣០នាទីយប់ បានធ្វើដំណើរទៅផ្ទះ **ត គ** ដោយ **អ ឩ** ជាអ្នកចង្អុលផ្លូវ ។ ទៅដល់ឃើញទ្វារផ្ទះចំហខាងក្រោយ **អ ឩ** នៅខាងក្រៅ ខ្លួន០៣នាក់ចូលទៅក្នុងផ្ទះ ខ្លួនជាអ្នកកាន់កាំភ្លើងឈរវេរា ឈ្មោះ **ឆ** កញ្ឆក់កាំភ្លើងពីខ្លួនទៅបណ្តាច់មុងរួចភ្ជង់ម្ចាស់ផ្ទះ ខ្លួនជាអ្នកចង ខ្លួនឃើញប្រពន្ធនឹងកូនតូចៗ តែខ្លួនពុំមានវាយធ្វើបាបអ្វីទេ គ្រាន់តែរុំចងមុខតែប៉ុណ្ណោះ ហើយសួររកលុយពីប្រពន្ធ ប្រពន្ធយកលុយមួយស្បោងមកអោយខ្លួន ចំណែក **ថ សរ** ជាអ្នកទៅដោះយកក្រវិលនឹងចិញ្ចៀន ។ ខ្លួនធ្វើសកម្មភាពរយៈពេលប្រហែលមួយម៉ោង ខ្លួនរើក្នុងទូមាសជាមួយ **ថ សរ** ចប់សកម្មភាពក្រុមខ្លួនចេញតាមទ្វារមុខ ដោយពុំបានស្រាយម្ចាស់ផ្ទះទេ ។ ពេលចេញមកវិញជួបជុំគ្នា នៅក្រោយវត្តស្លាកែត រាប់លុយឃើញបាន ២០ម៉ឺន ចិញ្ចៀនមួយវង់ ក្រវិលប្លាទីនមួយគូ រួចហើយ **ថ សរ** និង **ឆ** ឡើងរ៉ឺម៉កទៅភ្នំពេញមុន ចំណែកខ្លួន និង **អ ឩ** ជិះឡានតាមក្រោយ មកដល់ភ្នំពេញ ខ្លួនទទួលបានប្រាក់ ៣៥.០០០រុ០០ ចំណែក **ឆ** គេសុំចែកលើស ចំពោះក្រវិល និង ចិញ្ចៀន **អ ឩ** និងឈ្មោះ **ឆ** ជាអ្នកយកទៅលក់ ក៏ត្រូវប៉ូលីសចាប់ រួចហើយប៉ូលីសចាប់ខ្លួននៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៥ នៅភ្នំពេញ ជាមួយឈ្មោះ **ថ សរ** ហើយបញ្ជូនទៅពន្ធនាគារខេត្តកណ្តាលនៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

-ជនជាប់ចោទឈ្មោះ **ថ សរ** បានឆ្លើយថា : មុនប្លន់មួយថ្ងៃ ខ្លួនជួបជុំគ្នានៅបឹងកក់ ដោយឈ្មោះ **ឆ** ជាអ្នកផ្តើមគំនិតបបួលទៅរកប្លន់នៅកៀនស្វាយ ទាំងអស់គ្នា ០៤នាក់ គឺរូបខ្លួន, **ថ សរ**, **ច សផ**, **ឆ**, និង **អ ឩ** លុះស្អែកឡើងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ទាំងបួននាក់ធ្វើដំណើរទៅកៀនស្វាយ ទៅដល់ម៉ោង ៥:០០ល្ងាច នៅច្រៀងខារ៉ាអូខេជិតវត្តស្លាកែត លុះម៉ោង ១:៣០នាទីយប់ **អ ឩ** ជាអ្នកបង្ហាញផ្លូវទៅប្លន់ ពេលទៅដល់ខ្លួនចូលទៅក្នុងផ្ទះ ០៣នាក់ ចំណែក **អ ឩ** ឈរយាមខាងក្រោយផ្ទះឈ្មោះ **ផ** កាន់កាំភ្លើងចូលមុន បន្ទាប់មក **ផ** ហុចឱ្យខ្លួន រួចហើយឈ្មោះ **ឆ** កញ្ឆក់កាំភ្លើងពីដៃខ្លួនទៅភ្ជង់ម្ចាស់ផ្ទះ រួចហើយ **ផ** ចាប់ចងម្ចាស់ផ្ទះ ខ្លួនអ្នកសំឡុតឱ្យម្ចាស់ផ្ទះយកលុយឱ្យខ្លួន ពេលនោះប្រពន្ធម្ចាស់ផ្ទះយកប្រាក់ឱ្យខ្លួនមួយកញ្ចប់ ឯឈ្មោះ **ឆ** ជាអ្នកទៅដោះយកក្រវិល និង ចិញ្ចៀន ពេលប្លន់ខ្លួនពុំបានវាយដំម្ចាស់ផ្ទះទេ ។ ប្លន់រួចក៏នាំគ្នាចេញតាមទ្វារមុខ រួចទៅជួបជុំគ្នានៅក្រោយវត្តស្លាកែត រាប់ឃើញប្រាក់ ២០ម៉ឺន ចំណែកខ្លួនបាន ៤៥.០០០រុ០០ ចំណែកដែលលើស **ឆ** ជាអ្នកយក ក្រវិល និង ចិញ្ចៀនឈ្មោះ **ឩ** នឹង **ឆ** យកទៅលក់ដើម្បីចែកគ្នា ។ តែពុំទាន់បានលក់ផង ខ្លួនត្រូវប៉ូលីសចាប់នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៥ នៅបឹងកក់ រួចបញ្ជូនមកខេត្តកណ្តាលនៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

-ជនរងគ្រោះឈ្មោះ **ត គ** បានឆ្លើយថា : នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ វេលាម៉ោង ១:៣០នាទីយប់ ខ្លួនដេកលក់ជាមួយប្រពន្ធកូន ០៤នាក់ នៅពេលដែលខ្លួនដឹង គឺឃើញមនុស្សប្រុសម្នាក់យកកាំភ្លើងទៅភ្ជង់សៀតថ្ក



Scanned with CamScanner

គំរាមមិនឱ្យស្រែក បើស្រែកគេនឹងបាញ់ចោល រួចអូសខ្លួនទៅចងនៅសសរកណ្ដាលផ្ទះ ហើយចងមាត់ចងដៃភ្ជាប់គ្នាវាម្នាក់ទៀតបានយកកាំភ្លើងទៅភ្ជង់ប្រពន្ធខ្លួនឱ្យយកប្រាក់ឱ្យវា ខ្លួនឃើញប្រពន្ធយកលុយមួយកញ្ចប់ទៅឱ្យវា ហើយអាម្នាក់ទៀតកកាយរើទូ ម្នាក់ចាប់អោបចងខ្លួនច្របាច់មាត់ខ្លួន វាធ្វើសកម្មភាពប្រហែលមួយម៉ោង ពេលវាដោះយកក្រវិល និង ចិញ្ចៀនពីប្រពន្ធខ្លួនអស់ហើយ វាក៏ចេញទៅដោយពុំមានវាយតប់អ្នកណាទេ កាំភ្លើងដែលវាកាន់ គឺ K៥៤ ។ ពេលវាចុះផុតកូនប្រុសខ្លួនចូលមកស្រាយ ហើយខ្លួនស្រែកឱ្យអ្នកជិតខាងជួយ រួចហើយអ្នកស្រុកចោមរោមជួយ ក្រោយមកទើបដឹងថាបាត់លុយ ២០ម៉ឺនរៀល មាស ០៣ជី ០៨ហ៊ុន ចិញ្ចៀនមួយវង់ ក្រវិលមួយគូ (ប្លាទីន) ពេលប្លន់ហើយទើបឮអ្នកស្រុកនិយាយថា ឃើញឈ្មោះ ឱ មកក្រវែលផ្ទះ តែខ្លួនពុំបានរាយការណ៍ជូនប៉ូលីសទេ ។ របស់ដែលខ្លួនបាត់ ខ្លួនយកបានក្រវិលមួយគូ ចិញ្ចៀនមួយវង់ ខ្លួនសំណូមពរប្តឹងទាមទារប្រាក់ ២០ ម៉ឺនរៀល និង មាស ០៣ជី ០៨ហ៊ុន ដែលជាលុយប្អូនផ្ញើទិញម៉ូតូវិញ ។

-តាមអំណានចម្លើយសាក្សីប៉ូលីសឈ្មោះ ស ខ បានឆ្លើយថា នៅយប់ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ១៩៩៥ វេលាម៉ោងប្រហែល ១:៣០នាទី ខ្លួនឮឆ្កែព្រុសរួចក៏ស្ងាត់ទៅវិញ ក្រោយមកទៀតខ្លួនឮសំឡេង ម៉េត និយាយនៅផ្ទះគាត់ជាប់ផ្ទះខ្លួនថា មានលុយឯណាអស់ហើយលុយ លុះគ្មានឮសំលេងអ្វីទៀតទេក៏សំរាន្តលក់ទៅ មួយសន្ទុះក្រោយមកឈ្មោះ គ ស្រែកប្រាប់ខ្លួនថា ជួយផង១ចោរប្លន់ផ្ទះខ្ញុំអស់ហើយ ខ្លួនក៏ស្រែកថាចោរ១ អ្នកស្រុកក៏ផ្អើលឆោឡោឡើង ។ ខ្លួនពុំដឹងថាចោរដើរទៅតាមផ្លូវណាទេ ហើយក៏មិនដឹងថាមានប៉ុន្មាននាក់ដែរ ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋាន : ឈ្មោះ **អ ឧ. ៩ សរ.** និងឈ្មោះ **ច សជ** បានសារភាពនូវអំពើរបស់ខ្លួនចំពោះមុខតុលាការអស់ហើយ ទាំងបីនាក់នេះមានចេតនាប្លន់ពិតប្រាកដណាស់ ព្រោះថាសកម្មភាពម្នាក់១ប្រហាក់ប្រហែលគ្នា គឺឈ្មោះ **អ ឧ.** ជាអ្នកបង្ហាញនាំផ្លូវ និង យាមកាមត្រឹមត្រូវ ចំណែកឯពីរនាក់ **៩ សរ** និង **ច សជ** គឺជាអ្នកដែលល់ក្នុងការរុករើទ្រព្យសម្បត្តិ និង ចាប់ចងម្ចាស់ផ្ទះ ដូច្នេះអំពើទាំងនេះ គឺដឹងខុសត្រូវ និងព្យាយាមទៀតផង ព្រោះថាមុនប្លន់មួយថ្ងៃ អ្នកទាំងបីបានទៅពិនិត្យមើលចងចាំទុកជាស្រេច ។

ដូច្នេះសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទទាំងបីតាមច្បាប់ ។

-អ្នកការពារជនជាប់ចោទ បានសន្និដ្ឋានការពារជនជាប់ចោទទាំងបីនាក់ថា មិនជំទាស់នឹងការចោទប្រកាន់របស់តំណាងអយ្យការទេ ក៏ប៉ុន្តែអំពើរបស់កូនក្ដីរបស់ខ្លួន ដែលស្ម័គ្រទៅប្លន់នេះ ពុំបានយល់ដឹងអំពីទោសកំហុស និងស៊ីជំរៅនូវអំពើរបស់ខ្លួនទេ ព្រោះថាគំរោងដែលទៅប្លន់នេះ គឺឈ្មោះ **ឌ** ជាផ្ដើមគំនិតនឹងបបួល ហើយដោយឃើញឈ្មោះ **ឌ** មានកាំភ្លើងផង ក៏ស្ម័គ្រចិត្តទៅដោយពុំពិចារណា ។ ម៉្យាងទៀតសកម្មភាពរបស់អ្នកទាំងបីពុំមានចិត្តក្លាហាន និង ពុំមានវាយជិះច្រំចាក់ទៅម្ចាស់ផ្ទះដែរ ពិសេសអ្នកទាំងបីបានសារភាពដោយស្មោះឥតលាក់លៀមនេះបញ្ជាក់ថា មិនយល់ពីអំពើដែលខ្លួនបានធ្វើនោះនឹងមានទោសយ៉ាងណាឡើយ ។ អាស្រ័យដោយមូលហេតុខាងលើ សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្ដីរបស់ខ្លួន ឱ្យបានវិលត្រលប់ទៅជួបជុំគ្រួសារកសាងសង្គមគ្រួសារឱ្យទៅជាពលរដ្ឋល្អត្រឹមត្រូវឡើងវិញ ។

-ជនជាប់ចោទឈ្មោះ **អ ឧ, ៩ សរ, ច សជ,** បានសំណូមពរជាចុងក្រោយថា សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់សាក្សី



Scanned with CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់អយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកការពារ

-ក្រោយពីបានស្តាប់ចម្លើយចុងក្រោយរបស់ជនជាប់ចោទ

**<u>តុលាការ</u>**

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

**<u>យល់ឃើញថា</u>**

-តំណាងអយ្យការចោទប្រកាន់លើជនជាប់ចោទ ពីបទប្លន់ នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ នៅចំណុចភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដូចនេះតុលាការនឹងពិចារណា វិនិច្ឆ័យសេចក្តីតាមការចោទនេះ ។

-មានសំអាងគ្រប់គ្រាន់បញ្ជាក់ថា : ពិតជាមានអំពើប្លន់កើតឡើងនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ វេលាប្រហែលម៉ោង ១:៣០នាទីយប់ ចំណុចភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ ខ សរ ឈ្មោះ អ ឧ ឈ្មោះ ច សដ សុទ្ធតែឆ្លើយដូចគ្នាថា ក្រុមខ្លួនមានគ្នាចំនួន ០៤នាក់ ដែលមានឈ្មោះ ឌ គ្មានសាវតារជាតិ និងពួកខ្លួនទាំងបីនាក់ ដែលជាចម្លើយ អាចយកជាការបានថា ជនល្មើសពិតជាមានគ្នាបួននាក់ប្រាកដមែន ។

-ចម្លើយរបស់ជនជាប់ចោទទាំងបី សុទ្ធតែឆ្លើយដាក់ថា ឈ្មោះ ឌ ជាមេគំនិត ដែលតុលាការពុំអាចជឿបានឡើយ ដោយពិនិត្យលើសកម្មភាពជនល្មើសដែលបានរៀបចំជាមុនពេលប្រព្រឹត្តល្មើស និង ក្រោយពីប្រព្រឹត្តបទល្មើសឃើញថា ជនជាប់ចោទឈ្មោះ អ ឧ ជាជនដែលបានស្គាល់ច្បាស់នូវផ្ទះរបស់ជនរងគ្រោះ ហើយជនបីនាក់ទៀតជាជនដែលចូលរួមធ្វើសកម្មភាពដោយផ្ទាល់ ។

-ជនជាប់ចោទទាំងបួននាក់ជាសមត្ថជន ដែលយល់ដឹងពីអំពើ និងបច្ច័យដែលកើតមានឡើងដោយអំពើរបស់ខ្លួន ដែលត្រូវទទួលខុសត្រូវទាំងស្រុងផ្នែកព្រហ្មទណ្ឌ ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ។

-ជនជាប់ចោទទាំងអស់សុទ្ធតែមានចេតនា និងព្យាយាមប្រព្រឹត្តបទល្មើសដោយហេតុថា ក្រុមនេះបានទៅដល់គោលដៅម្តងហើយនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៥ តែដោយមូលហេតុមិនអំណោយផលខ្លួនបានត្រលប់មកវិញ ហើយចេញដំណើរទៅប្រព្រឹត្តបទល្មើសនៅគោលដៅដដែល រហូតបានសម្រេចនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ វេលាម៉ោង ១:៣០នាទីយប់ ។

-ជនរងគ្រោះទទួលបាននូវចិញ្ចៀនប្លាទីនមួយវង់ និងក្រវិលមួយគូ ពីតុលាការនៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥ រួចហើយ ។

-អំពើរបស់ជនជាប់ចោទ បានរំលោភបំពានលើច្បាប់ព្រហ្មទណ្ឌជាធរមាន និងរំលោភយកទ្រព្យ ដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ។

-អំពើរបស់ជនជាប់ចោទប្រព្រឹត្តឡើងដោយហិង្សា ដោយប្រើប្រាស់អាវុធរំលោភលើរូបរាយ និងគំរាមស្មារតីជនរងគ្រោះ ឱ្យព្រមប្រគល់ទ្រព្យមកឱ្យក្រុមខ្លួន និង បង្ខំឱ្យជនរងគ្រោះស្ថិតក្នុងស្ថានភាពពុំអាចតទល់ ឬ ការពារទ្រព្យខ្លួនបាន ។

-អំពើរបស់ជនជាប់ចោទប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខសាធារណៈ ។

Scanned with CamScanner

-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទឈ្មោះ **អ ឧ** ឈ្មោះ **ឲ សរ** ឈ្មោះ **ច សឲ** ពិតជាបានប្រព្រឹត្ត បទប្លន់ នៅចំណុចភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីយប់ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ប្រាកដមែន ។

បទល្មើសដែលមានចែង និងបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-មាត្រា ៣៤ ចែងថា :

១-ជនណាក៏ដោយដែលលួចប្លន់ ឬល្បងលួចជនម្នាក់ទៀតក្នុងករណីធ្ងន់ធ្ងរ ទម្ងន់ទោស :

-ដូចជាការលួចប្លន់នោះ ធ្វើឡើងដោយអំពើឃោរឃៅ ប្រើអាវុធក៏ដោយ មិនប្រើអាវុធក៏ដោយនាំឱ្យមានរបួសក្ដី ឬមិនមានរបួសក្ដី ។

-ឬការលួចនោះធ្វើឡើងដោយច្រើនគ្នា ឬដោយមានការគាស់ទំលុះទំលាយ នឹងត្រូវទទួលកំហុសតាមបទឧក្រិដ្ឋជាអំពើលួចប្លន់ ហើយត្រូវផ្ដន្ទាទោសឃុំឃាំងជាបទឧក្រិដ្ឋពី ០៣ឆ្នាំ ទៅ ១០ ឆ្នាំ ។

២-អំពើលួចប្លន់ គឺការបន្លំយកទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធរបស់ខ្លួន ។

-ជនជាប់ចោទឈ្មោះ **ឌ** គេចខ្លួនគ្មានសាវតារជាតិ ហើយតំណាងអយ្យការបានបង្អង់បណ្ដឹងអាជ្ញា ដូចនេះតុលាការពុំលើកយកជនជាប់ចោទរូបនេះមកវិនិច្ឆ័យទោសនាពេលនេះឡើយ ។

-ជនរងគ្រោះ និង ជាដើមបណ្ដឹងរដ្ឋប្បវេណី បានទាមទារសំណងអន្តរាយចំនួនប្រាក់ ២០ម៉ឺនរៀល និងមាសចំនួន ០៣ជី ០៨ហ៊ុន ដែលតុលាការនឹងលើកយកពិចារណាសម្រេចសេចក្ដី ឱ្យបានសមស្របតាមព្យសនកម្ម ។

-មានសំអាងច្បាស់លាស់ដែលតុលាការជឿបានថា : ជនរងគ្រោះពិតជាបានបាត់បង់នូវមាសចំនួន ០៣ជី ០៨ហ៊ុន ក្រវិលប្លទីនមួយគូ ចិញ្ចៀនមួយវង់ ព្រមទាំងប្រាក់ចំនួន ២០ម៉ឺនរៀលប្រាកដមែន ដោយហេតុថា ទោះបីជាជនជាប់ចោទ ពុំបានឆ្លើយនៅចំពោះមុខសវនាការក្ដី ប៉ុន្តែមានចម្លើយរបស់ឈ្មោះ **ឲ សរ** ដែលតុលាការចាត់ទុកជាបានការ នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៥ ដែលថាខ្លួនប្លន់យកបានមាស ០៣ជី ក្រវិលមួយគូ ចិញ្ចៀនមួយវង់ និងប្រាក់ ២០ម៉ឺនរៀល ដូចគ្នានឹងចម្លើយជនរងគ្រោះឈ្មោះ **ឃ ម** ដែលជាប្រពន្ធឈ្មោះ **ត គ** ។

-សេចក្ដីសន្និដ្ឋានរបស់អ្នកការពារ ដែលថាជនជាប់ចោទគ្មានបំណងប្លន់ជាមុន ជាចម្លើយដែលតុលាការពុំអាចយកជាការបានឡើយ ដោយជនជាប់ចោទនេះបានឆ្លើយបង្ហាញច្បាស់ថា ខ្លួនបានជួបជុំគ្នាជាមុននៅភ្នំពេញ ហើយចេញដំណើរក្នុងគោលដៅប្លន់នៅភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ត្រង់ចំនុចផ្ទះជនរងគ្រោះឈ្មោះ **ត គ** ។

## <u>ហេតុដូចនេះសំរេច</u>

១-ផ្ដន្ទាទោស :

ក-ឈ្មោះ **អ ឧ** ភេទប្រុស កើតឆ្នាំ ១៩៧៣ កំណត់ដាក់ពន្ធនាគារចំនួន ០៦ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃ ទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

ខ-ឈ្មោះ **ឲ សរ** ភេទប្រុស កើតឆ្នាំ ១៩៧២ កំណត់ដាក់ពន្ធនាគារចំនួន ០៦ឆ្នាំ គិតពីថ្ងៃទីឃុំខ្លួន



Scanned with CamScanner

ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

គ-ឈ្មោះ **ច សផ** ភេទប្រុស កើតឆ្នាំ ១៩៧០ កំណត់ដាក់ពន្ធនាគារចំនួន ០៦ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

ពីបទ : ប្លន់ ប្រព្រឹត្តនៅចំណុចភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីយប់ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ។ បទល្មើសដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

២-អោយឈ្មោះ **អ ឧ. ថ សរ.** និង **ច សផ** រួបរួមគ្នាសងសំណងជាប្រាក់ចំនួន ២០ម៉ឺនរៀល និងមាស ០៣ជី (មាសទឹក៩៧) ទៅជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ត គ** នាពេលសាល-ក្រមស្ថាពរ ។ ករណីជនទាំបីខាងលើគ្មានទ្រព្យធនសងធនទណ្ឌគ្រប់គ្រាន់ទេ ត្រូវដាក់គុកបង្ខំរូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ ។

៣-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខ បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល ០២ខែ គិតពីថ្ងៃនេះតទៅ ។

**ចៅក្រមជំនុំជំរះ**

[redacted]

---

សេចក្តីប្រកាសនេះ ព្រះករុណាព្រះចៅក្រុងកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីអនុវត្តសាលក្រមឱ្យសម្រេចតាមសាលក្រមនេះ និងឱ្យអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ជួយផ្តល់កំលាំង ដើម្បីសម្រេចការអនុវត្តនេះ បើមានសំណុំរឿងត្រឹមត្រូវតាមផ្លូវច្បាប់ ។

**បានឃើញ**

**ប្រធានតុលាការ**

[redacted]

*កណ្តាល. ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦*

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner